**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកនៅផ្សារតូច**
**ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៨**
***គឺអ្នកហ្នឹងឯង***

អត្ថបទទី១៖ កក ២,១-១១
អត្ថបទទី២៖ កាឡ ៥,១៦-២៥
ដំណឹងល្អ៖ យហ ១៥,២៦-២៧.១៦,១២-១៥

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមានអំណរសប្បាយពិតមែន យើងមានកម្លាំងមួយយ៉ាងពិសេសពិតមែន។ អំណរសប្បាយនេះ ប្រសិនបើយើងមានពិតមែនជាសញ្ញាសំគាល់នៃព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងពិសេសគឺអំណរសប្បាយ។

ថ្ងៃនេះយើងបានស្តាប់នៅក្នុងគម្ពីរដំណឹងល្អ អំពីព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះយេស៊ូកំពុងរៀបចំដើម្បីឲ្យក្រុមគ្រីស្តទូតទទួល ដើម្បីឲ្យយើងទាំងអស់ទទួល និងព្រះវិញ្ញាណដ៏វិសុទ្ធនេះ ជាព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្តីពិត។ **ព្រះវិញ្ញាណនៃសេចក្តីពិត** ដែលណែនាំឲ្យយើងធ្វើដំណើរដើម្បីជួបសេចក្តីពិតដ៏ពេញលក្ខណៈ និងព្រះវិញ្ញាណនេះនឹងធ្វើរបាយការណ៍អំពីអ្វីៗទាំងអស់ដែលព្រះយេស៊ូធ្លាប់បានប្រាប់ដល់យើង។ ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះពន្លឺនៃសេចក្តីពិត ដែលណែនាំឲ្យយើងនឹកឃើញអ្វីៗទាំងអស់ដែលកើតឡើងនៅក្នុងប្រវត្តិសាស្រ្តនៃពិភពលោកពីដើម នៅក្នុងជីវិតរបស់យើងពីដើម នៅក្នុងជីវិតនៃព្រះសហគមន៍ពីដើម និងណែនាំឲ្យយើងមើលឃើញអនាគត។ មានន័យថាព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដើម្បីឲ្យយើងយល់ដឹងយ៉ាងច្បាស់អំពីអតីតកាល និងដើម្បីឲ្យយើងមើលឃើញអំពីអនាគត ដើម្បីរស់នៅក្នុងបច្ចុប្បន្ននេះ។ នេះជាព្រះវិញ្ញាណដ៏វិសុទ្ធធ្វើដំណើរជាមួយយើងបច្ចុប្បន្ននេះ ដើម្បីមើលឃើញអតីតកាល និងដើម្បីឲ្យយើងធ្វើដំណើរទៅថ្ងៃអនាគតផង។

ថ្ងៃនេះជាថ្ងៃពិសេស ដោយសារថ្ងៃនេះយើងមានបងប្អូន៣០នាក់(សាមសិបនាក់) ដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដោយសារថ្ងៃនេះយើងរួមគ្នាជាមួយព្រះសហគមន៍ដែលនិយាយភាសាផ្សេងៗគ្នានៅក្នុងអំណរសប្បាយ។ សម្រាប់បងប្អូនដែលធ្លាប់ស្តាប់ព័ត៌មានថ្ងៃនេះជាថ្ងៃបុណ្យជាតិ ជាថ្ងៃដំបូងនៃប្រវត្តិសាស្រ្តកម្ពុជា ដែលរាជរដ្ឋាភិបាលឲ្យយើងគោរពថ្ងៃបុណ្យជាតិថ្មីគឺបុណ្យ "ការចងចាំ" ចងចាំអំពីអ្វី? គឺចងចាំនឹករឭកអំពីវិញ្ញាណក្ខន្ធរបស់ប្អូនដែលបានទទួលមរណភាពនៅក្នុងសម័យខ្មែរក្រហម និងដល់បងប្អូនដែលបានរង

ទុក្ខលំបាកនៅក្នុងសម័យខ្មែរក្រហម។ ប៉ុន្មានអាទិត្យមុននៅតាំងគោក នៅថ្ងៃទី០១ ខែឧសភា យើងបានប្រារព្ធពិធីបុណ្យនេះហើយ ដើម្បីឲ្យយើងរួមគ្នាជាព្រះសហាគមន៍អធិដ្ឋានតាមរយៈវិញ្ញាណក្ខន្ធរបស់មរណសាក្សីយើង ដល់បងប្អូនខ្មែរយើងទាំងអស់ដែលបានទទួលមរណភាព មានជិត២លាននាក់ និងដល់បងប្អូនដែលបានរងទុក្ខលំបាក និងដែលរស់នៅសព្វថ្ងៃដោយនឹកឃើញទុក្ខលំបាក ភាពងងឹតនៃជីវិត ប៉ុន្តែដោយនឹកឃើញអនាគតដែរ។

ដូច្នេះថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងចងចាំដែរ ឲ្យយើងនឹកឃើញប្រវត្តិសាស្ត្រនៃពិភពលោកទាំងមូល យើងអាចនិយាយថា ប្រវត្តិសាស្ត្រនៃពិភពលោកទាំងមូលធ្វើដោយអំណរសប្បាយ ធ្វើដោយសិរីរុងរឿង ធ្វើដោយការអស្ចារ្យនៃការអភិវឌ្ឍពីមួយជំនាន់ទៅមួយជំនាន់។ ដោយសារមនុស្សដើមគេអត់មានភ្លើង មនុស្សដើមគេអត់មានផ្ទះមនុស្សដើមអត់មានអ្វីសោះ។ សព្វថ្ងៃសតវត្សរ៍ទី២១ យើងបានឡើងដល់កំពូលនៃឯកទេស និងសម្រាប់ថ្ងៃស្អែកយើងឡើងដល់កំពូលនៃឯកទេសថែមទៀត ដែលយើងនឹកមិនដល់។ ប៉ុន្តែប្រវត្តិសាស្ត្រនៃមនុស្សលោក ធ្វើដោយអំពើងងឹតដែរ ធ្វើដោយអំពើឃោឃៅដែរ ធ្វើដោយសង្គ្រាមដែរ ធ្វើដោយទុក្ខលំបាក និងទុក្ខវេទនាយ៉ាងច្រើន នេះជាសេចក្តីពិត។

ដូច្នេះថ្ងៃនេះដែលយើងប្រារព្ធថ្ងៃបុណ្យចងចាំ ជាពេលវេលាមួយដើម្បីឲ្យយើងរួមគ្នាអាចប្រកាសថា យើងជាគ្រីស្តបរិស័ទកាតូលិក ជាសាវ័ករបស់ព្រះយេស៊ូយើងចង់រស់នៅក្នុងពិភពលោកមួយ ប្រកបដោយសុខសន្តិភាពនិងគោរពគ្នាទៅវិញទៅមក ប្រកបដោយសុខដុមរមនានិងការលើកលែងទោសឲ្យគ្នាទៅវិញទៅមក ប្រកបដោយយុត្តិធម៌និងសេចក្តីពិតដ៏ពិតប្រាកដ។ នេះជាគោលបំណង នេះជាទស្សនៈ នេះជាឆន្ទៈរបស់យើង ដើម្បីប្រគល់ពិភពលោកមួយយ៉ាងស្អាតបំផុត ដល់កូនចៅរបស់យើងដែលបំផ្លាញគ្រប់អំពើអាក្រក់ ដែលបំផ្លាញគ្រប់សង្គ្រាម ដើម្បីរស់នៅក្នុងជីវិតដែលព្រះជាម្ចាស់រៀបចំសម្រាប់យើងមានន័យថាព្រះរាជ្យរបស់ព្រះជាម្ចាស់ផ្ទាល់។ ប៉ុន្តែថ្ងៃនេះជាឱកាសមួយ ដោយសារយើងទទួលព្រះវិញ្ញាដ៏វិសុទ្ធ ដែលជាព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្តីពិត ដើម្បីសួរសំណួរដល់ខ្លួនឯង សួរសំណួរដល់យើងដែលជាគ្រីស្តបរិស័ទ ដែលជាមិត្តសម្លាញ់របស់ព្រះយេស៊ូ តើយើងចង់ផ្តល់សង្គម(ពិភពលោក) អ្វីខ្លះដល់កូនៗរបស់យើង ដល់កូនចៅរបស់យើង? យើងឃើញកូនៗ៣០នាក់ដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាសថ្ងៃនេះ មួយចំនួននៅ

ក្មេងណាស់ នៅថ្ងៃស្អែកគេបង្កើតគ្រួសារ នៅខានស្អែកគេមានកូន គេចង់ឲ្យកូនៗរបស់គេរស់នៅក្នុងពិភពលោកដូចម្តេច? នៅពេលយើងបើកភ្នែកបន្តិចពេលយើងមើលព័ត៌មាននៅក្នុងពិភពលោកទាំងមូល ជួនកាលយើងចង់ភ្ញាក់ ជួនកាលយើងចង់ញាក់សាច់ ជួនកាលយើងចង់ភ័យ ជួនកាលយើងចង់ព្រឺសម្បុរ ជួនកាលយើងចង់ខ្លាចមែនទែន ដោយសារពេលយើងមើលពិភពលោកសព្វថ្ងៃ និងថ្ងៃនេះយើងមានបងប្អូនមកពីគ្រប់ទិស នៅក្នុងពិភពលោកទាំងមូល ពីខាងកើតខាងលិច ខាងជើង ខាងត្បូង យើងមកពីទ្វីបទាំងអស់នៅថ្ងៃនេះ។ ប្រសិនបើយើងបើកភ្នែក ពីទឹកដីកម្ពុជារបស់យើង ពេលយើងមើលតាមព័ត៌មានយើងទទួលពីមួយថ្ងៃទៅមួយថ្ងៃ ជួនកាលយើងភ្ញាក់ យើងភ័យ យើងសប្បាយផង ។ យើងភ្ញាក់ដោយសារយើងឃើញប្រទេស ដែលមានអំណាចជាងគេនៅក្នុងពិភពលោក ប្រទេសដែលចង់ដឹកនាំពិភពលោកទាំងមូល សព្វថ្ងៃអ្នកដឹកនាំប្រទេសហ្នឹង គាត់ដឹកនាំប្រទេសរបស់គាត់ ដោយផ្សាយព័ត៌មាន ផ្សាយការសម្រេចចិត្តតាម Twitter ។ នេះជាសំណួរមួយយើងដឹកនាំប្រទេសយើងដោយ Twitter ដូចម្តេចបាន? នេះជាសំណួរតែប៉ុណ្ណឹង ខ្ញុំមិនវិនិច្ឆ័យទេ។ ហើយប្រសិនបើយើងមើលនៅជិតៗក្នុងទ្វីបអាស៊ីរបស់យើង យើងមានប្រទេសមួយដែលសព្វថ្ងៃ មានការដឹកនាំដោយបិទសិទ្ធិសេរីភាពរបស់មនុស្ស បិទអ្វីៗទាំងអស់ និងកំពុងលេងជាមួយពិភពលោកទាំងមូល ដោយគំរាម "បន្តិចទៀតយើងអាចប្រើមីលស៊ីលអាតូមិក ដើម្បីបាញ់ទៅកន្លែងណាដែលយើងចង់បាញ់"។ ជួនកាលយើងមានអារម្មណ៍ថាគេលេងជាមួយពិភពលោក ដូចគេលេងហ្គេម ដូចក្មេងៗនិងយុវជនចូលចិត្តដែរ ។ ប៉ុន្មានអាទិត្យ យើងបានឃើញគេបានបាញ់ប្រទេសស៊ីរីនៅទ្វីបអឺរ៉ុប ដោយបានប្រើមីលស៊ីលយ៉ាងច្រើនដែលថ្លៃណាស់។ មីលស៊ីលមួយ១លានដុល្លា ២លានដុល្លា ហើយគេបានបាញ់ប៉ុន្មានរយមីលស៊ីលហ្នឹង។ ហេតុនេះហើយនៅពេលបាញ់មីលស៊ីលម្តង បានលុយច្រើនសម្រាប់រោងចក្រដែលផលិតអាវុធនានា។ ប៉ុន្តែនៅពេលនោះដដែលមានមនុស្សជាច្រើនដែលស្លាប់ បាត់បង់ជីវិត កូនក្មេង យុវជន មនុស្សដែលអត់បានធ្វើអ្វីខុស។ មានប្រទេសដែលពោរពេញដោយសេរីភាព ណែនាំឲ្យប្រជាជនមានសំឡេងតាមចិត្តគេ នៅពេលនោះគេកំពុងបាតុកម្មនេះ បាតុកម្មនោះ ដោយសារបុគ្គលិកនៃក្រុមហ៊ុននានាគេគិតថាប្រាក់ខែគេថោកពេក។ ដូច្នេះនៅក្នុងប៉ុន្មានអាទិត្យគេបានបាត់បង់លុយ រាប់រយលានដុល្លា ដោយសារប្រជាជនជាអ្នកបាតុកម្មបាតុកម្មនិងការងារអត់ទៅមុខ។ បងប្អូនដែលបានមើលទូរទស្សន៍ពីម្សិលមិញ អ្នកណាក៏បានមើល អឺរ៉ុប និងអាស៊ីនៅឆ្ងាយពីគ្នាបន្តិច។ ម្សិល

មិញខ្ញុំចាក់ជដែកជាមួយម្ដាយខ្ញុំ ម្ដាយខ្ញុំថា "កូនអើយ! ខ្ញុំកំពុងរវល់មើលទូរស្សន៍អំពីពិធីអាពាហ៍ពិពាហ៍របស់កូនព្រះមហាក្សត្រនៅប្រទេសអង់គ្លេស"។ អាពាហ៍ពិពាហ៍នេះដែលណែនាំឲ្យមនុស្សរាប់ពាន់នាក់ដែលជាភ្ញៀវកិត្តិយសដែលចាយលុយសម្រាប់ម្ហូបអាហារ ធ្វើការអស្ចារ្យមែន។ ប៉ុន្តែនៅពេលនោះដដែលយើងឃើញកូនក្មេងប៉ុន្មានលាននាក់ ដែលកើតមកអត់មានម្ហូបអាហារ អត់មានគ្រួសារត្រឹមត្រូវ អត់មានផ្ទះដើម្បីដេក អត់មានអត្តសញ្ញាណប័ណ្ណយ៉ាងពិតប្រាកដ។ ពីមួយថ្ងៃទៅមួយថ្ងៃនៅប្រទេសដែលកំពុងអភិវឌ្ឍន៍ គេពូកែរៀបចំជប់លៀង ជប់លៀងដើម្បីប្រមូលលុយ ជប់លៀងដើម្បីទៅជួយអ្នកក្រីក្រ ដើម្បីមនុស្សធម៌។ ប៉ុន្តែជារៀងរាល់ថ្ងៃនៅភ្នំពេញថ្មីដែលខ្ញុំស្នាក់នៅសព្វថ្ងៃ ខ្ញុំឃើញកូនក្មេង ខ្ញុំឃើញយុវជន ខ្ញុំឃើញមនុស្សពេញវ័យ លោកតាលោកយាយដែលកំពុងរើសសំរាម ដើម្បីខិតខំរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដោយញ៉ាំម្ហូបដែលនៅសល់ ឬលក់អ្វីដែរគេអាចលក់បាននៅក្នុងសំរាមហ្នឹង។ ប៉ុន្តែយើងដឹងថា នៅក្នុងពិភពលោករបស់យើង គម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ គម្រោងការដ៏អស្ចារ្យរបស់ព្រះយេស៊ូ គឺបង្កើតព្រះរាជ្យរបស់ព្រះអង្គដែលអត់ទាន់មកដល់ ហើយយុត្តិធម៌អត់ទាន់ពេញ សេចក្ដីសុខសាន្តអត់ទាន់ពេញ សុភមង្គលអត់ទាន់ពេញលក្ខណៈ។ ជួនកាលខ្ញុំសួរខ្លួនឯងថា ប្រសិនបើថ្ងៃនេះព្រះយេស៊ូត្រឡប់មកវិញ? ប្រសិនបើថ្ងៃនេះព្រះយេស៊ូចុះនៅទីនេះ នឹងមើលបងប្អូនយើងទាំងអស់ដែលកំពុងអង្គុយស្ដាប់ ប្រហែលព្រះយេស៊ូសួរ "**បងប្អូនជាទីស្រឡាញ់ យើងកំពុងបង្កើតពិភពលោកដូចម្ដេច?**" ពេលនោះប្រហែលព្រះយេស៊ូបន្ថែមថា "ឥលូវនេះបងប្អូនជាទីស្រឡាញ់ខ្ញុំផ្ញើជូនព្រះវិញ្ញាណដ៍វិសុទ្ធនៃសេចក្ដីពិត ដើម្បីឲ្យបងប្អូនទាំងអស់អាចនឹករឮកអានសារជាថ្មីគ្រប់ព្រឹត្តិការណ៍ដែលកំពុងកើតឡើង នៅក្នុងពិភពលោក នៅក្នុងសង្គម នៅក្នុងព្រះសហគមន៍ នៅក្នុងជីវិតផ្ទាល់របស់បងប្អូន"។ ហើយនៅពេលនោះខ្ញុំជាព្រះយេស៊ូ "ខ្ញុំជាព្រះយេស៊ូ ខ្ញុំអញ្ជើញប្អូនសុំឈរឡើង! ដើម្បីរស់នៅនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃនេះ នៅសព្វថ្ងៃ នៅក្នុងពិភពនៃសម័យបច្ចុប្បន្ននេះ"។ ខ្ញុំជឿថា នេះជារបៀបដែលព្រះយេស៊ូនិយាយដល់យើងថ្ងៃនេះ។ យើងអត់មើលឃើញព្រះយេស៊ូចុះពីស្ថានបរមសុខ ដើម្បីនិយាយជាមួយយើង ប៉ុន្តែតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃនេះនៅក្នុងដួងចិត្តរបស់យើងរៀងៗខ្លួន ព្រះវិញ្ញាណដ៏សុទ្ធយាងចុះដើម្បីឲ្យយើងស្ដាប់សំណួរសំខាន់ ប្អូនអើយ!កំពុងកសាងពិភពលោកដូចម្ដេច? និងដើម្បីឲ្យយើងស្ដាប់ព្រះបន្ទូលដ៏សំខាន់នេះសូមក្រោកឈរ

ឡើង ដើម្បីរស់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៃសេចក្តីពិត និងដើម្បីទៅប្រកាសអំពីសេចក្តីស្រឡាញ់នៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី។

បងប្អូនដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធបន្តិចទៀត មានអំណរសប្បាយដោយសារបន្តិចទៀតទទួលព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអំណោយទាននៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺអ្វីដែលណែនាំឲ្យយើងអាចអនុវត្តការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូរស់នៅសព្វថ្ងៃនេះ នៅក្នុងពិភពលោករបស់យើង ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំយើងដោយសារព្រះអំណោយទានគឺ ប្រាជ្ញាឈ្លាសវៃ ដឹងខុសដឹងត្រូវ ទទួលព្រះវិញ្ញាណនៃសេចក្តីពិត ឲ្យមានយោបល់ល្អ ឲ្យមានសេចក្តីក្លាហាននិងសេចក្តីអង់អាច ដើម្បីរស់នៅនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដោយស្គាល់ និងកោតខ្លាចព្រះជាម្ចាស់។ គ្រប់ព្រះអំណោយទាននេះណែនាំឲ្យយើងអាចរស់នៅជាគ្រីស្តបរិស័ទដ៏ពិតៗនៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីប្រកាសដំណឹងល្អ ដែលព្រះយេស៊ូបានចាប់ផ្តើមប្រកាសនៅស្រុកកាលីឡេ២០០០ឆ្នាំមុន ដែលព្រះយេស៊ូទន្ទឹងរង់ចាំលើយើងនៅថ្ងៃនេះនៅឆ្នាំ២០១៨ ដើម្បីឲ្យយើងបន្តប្រកាសដំណឹងល្អ កុំឲ្យយើងអស់សង្ឃឹមដោយសារយើងដឹងថា យើងពោរពេញដោយវិញ្ញាណរបស់ព្រះជាម្ចាស់ផ្ទាល់ ដែលណែនាំឲ្យយើងមានកម្លាំងដ៏បរិបូរណ៍ ដើម្បីរស់នៅជាគ្រីស្តបរិស័ទយ៉ាងជាក់ស្តែង ដែលផ្តល់សក្ខីភាពយ៉ាងជាក់ស្តែងនៅក្នុងសង្គមបច្ចុប្បន្ននេះ។

ហេតុនេះហើយ បងប្អូនជាទីស្រឡាញ់! សូមឲ្យយើងយកចិត្តទុកដាក់ដើម្បីឲ្យផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយើងបានស្តាប់អម្បាញ់មិញ នៅក្នុងអត្ថបទទី២ **ផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធហៀរចេញពីដួងចិត្ត ពីភាពញញឹម ពីភ្នែក ពីដៃរបស់យើង**។ សូមឲ្យផ្លែនៃសេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោសមេត្តា ជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង សូមឲ្យផ្លែហ្នឹងហៀរពីគ្រប់ទីកន្លែងនៃដួងចិត្តរបស់យើង ដើម្បីឲ្យយើងរស់នៅនៅក្នុងពិភពមួយដែលបន្តិចៗម្តងដោយកែប្រែ។ កែប្រែដើម្បីឲ្យយើងទុកមរតកដល់កូនចៅរបស់យើង មិនមែនឲ្យរស់នៅក្នុងប្រទេស នៅក្នុងពិភពមួយដែលវង្វេងស្មារតី គិតតែអំពីផ្ទាល់ខ្លួន អាត្មានិយមទៅជាអតិភាព។ ប៉ុន្តែផ្ទុយទៅវិញដើម្បីឲ្យព្រះយេស៊ូទៅជាអតិភាពមុនគេបង្អស់។

ហេតុនេះហើយ ឲ្យយើងចាប់ផ្តើម! ឲ្យយើងចាប់ផ្តើមនៅកន្លែងណា?

ទី១) នៅក្នុងក្រុមគ្រួសាររបស់យើង សព្វថ្ងៃនៅក្នុងភូមិភាគភ្នំពេញយើងនៅក្នុងឆ្នាំគ្រួសារ ២០១៧-២០២០ ឲ្យយើងសម្លឹងមើលក្រុមគ្រួសារដ៏វិសុទ្ធ (ព្រះនាងម៉ារី លោកយ៉ូសែប និងព្រះកុមារយេស៊ូ) នេះជាគំរូរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រុមគ្រួសារដ៏សាមញ្ញពិតមែនដែលព្រះជាម្ចាស់ជ្រើសរើស ប៉ុន្តែក្រុមគ្រួសារដែលរស់នៅដោយការងារផ្ទាល់ខ្លួន ដែលណែនាំឲ្យកូនយេស៊ូ ចេះអធិដ្ឋាននិងស្គាល់ព្រះបិតា បង្កើតទំនាក់ទំនងជាមួយអ្នកជិតខាងយ៉ាងជិតស្និទ្ធ យកចិត្តទុកដាក់ជាមួយអ្នកជិតខាងដែលកំពុងខ្វះខាត រស់នៅដោយចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក ពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងក្រុមគ្រួសារ។ ឲ្យយើងចាប់ផ្ដើមចេញពីក្រុមគ្រួសាររបស់យើង ដើម្បីឲ្យក្រុមគ្រួសាររបស់យើងអាចរស់នៅក្នុងការអធិដ្ឋានពិត ការគោរពគ្នាទៅវិញទៅមក ការចែករំលែកជាមួយអ្នកដែលកំពុងខ្វះខាត។ ឲ្យគ្រួសាររបស់យើង ដូចអ្នកដែលរៀបការបានរើសយកអត្ថបទនេះប៉ុន្មានដងប៉ុន្មានសារ "**ទៅជាអំបិល និងពន្លឺសម្រាប់សង្គមបច្ចុប្បន្ននេះ**"។ នៅពេលគ្រួសារខ្សោយនៅក្នុងសង្គមមួយ សង្គមខ្សោយទៅៗ នៅពេលគ្រួសាររឹងមាំក្នុងសង្គមមួយ សង្គមហ្នឹងរឹងមាំទៅៗ។ ដូច្នេះសម្រាប់យើងជាគ្រីស្តបរិស័ទតិចក៏ដោយ ឲ្យយើងចាប់ផ្ដើមពីពេលនេះតទៅដើម្បីឲ្យគ្រួសាររបស់យើង ទៅជាគ្រួសារដ៏គំរូតាមរបៀបក្រុមគ្រួសារដ៏វិសុទ្ធ។

ទី២) នៅក្នុងព្រះសហគមន៍របស់យើង ជាពិសេសបងប្អូន៣០នាក់នេះកុំឲ្យទៅជាគ្រីស្តបរិស័ទខ្ជិល កុំឲ្យយើងធ្វើជាគ្រីស្តបរិស័ទដែលមិនដឹងខ្លួន! កុំឲ្យយើងធ្វើគ្រីស្តបរិស័ទល្មមៗ! នេះជាគ្រោះថ្នាក់បំផុត! សូមឲ្យយើងធ្វើជាគ្រីស្តបរិស័ទល្អឥតខ្ចោះតាមព្រះយេស៊ូ ឲ្យយើងគ្រីស្តបរិស័ទដែលចេញកម្លាំងទាំងអស់តាមព្រះយេស៊ូ។ នៅក្នុងព្រះសហគមន៍យើងចូលវិហាររាល់អាទិត្យ មនុស្សតិចឬច្រើនអត់អីទេ លោកឪពុកថ្វាយអភិបូជាដដែល។ ប៉ុន្តែឲ្យយើងមានជំនឿរឹងមាំ កុំឲ្យយើងយកអតិភាពរកស៊ី។ ឲ្យយើងនៅក្នុងព្រះវិហាររបស់យើង យើងចេះអធិដ្ឋាន ជាពេលវេលាចេះស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យយើងមានសកម្មភាពដើម្បីជួយតាមគណៈកម្មការសង្គហៈ ក្រុមនីមួយៗដែលយើងមាន និងទទួលអគ្គសញ្ញានៃជីវិត (ព្រះកាយព្រះគ្រីស្ត អគ្គសញ្ញាលើកលែងទោស)។

ទី៣) សូមឲ្យយើងរស់នៅក្នុងសង្គម នៅក្នុងជីវិតរបស់យើងបច្ចុប្បន្ន។ យើងអត់ត្រូវការប្រកាសខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំជាមនុស្សល្អ។ ចូរធ្វើទៅៗ បង្ហាញទៅ! ម្សិលមិញខ្ញុំរំឮកសម្រាប់យើងជាគ្រីស្តបរិស័ទ យើងមានធម្មវិន័យរបស់ព្រះយេស៊ូតែមួយគត់ដែលយើងត្រូវ

ការចាំ និងអនុវត្ត "សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំស្រឡាញ់អ្នករាល់គ្នា"។ រស់នៅតាមនេះ ណែនាំឲ្យយើងអាចចូលរួមនៅក្នុងសង្គមយ៉ាងសកម្ម ដើម្បីឲ្យសង្គមរបស់យើងមានយុត្តិធម៌ថែមទៀត មានសាមគ្គីភាពថែមទៀត ចេះថែរក្សាបរិស្ថានធម្មជាតិថែមទៀត ចេះគោរពគ្នាទៅវិញទៅមកថែមទៀត។ ដោយសារមូលហេតុតែមួយ "ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"។

បងប្អូនជាទីស្រឡាញ់! ប្រសិនបើយើងអនុវត្តតាមនេះ ប្រសិនបើយើងយកចិត្តទុកដាក់ អ្វីៗដែលខ្ញុំនិយាយហើយ បន្តិចទៀតនៅពេលយប់ នៅពេលដែលយើងងើបមើលផ្ទៃមេឃងងឹត យើងមើលឃើញផ្កាយរាប់លានដែលភ្លឺ ដែលមានរស្មីចេញដល់ផែនដីយើង ផ្កាយនីមួយៗមានឈ្មោះច្បាស់លាស់ គឺអ្នកហ្នឹងឯង។

អាម៉ែន! អាលេលូយ៉ា! ជយោព្រះវិញ្ញាណដ៏វិសុទ្ធ!!!